ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤៦៥

ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៣

សាលដីកា

លេខ : ១៩៨

ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៤

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ០៩ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ខិត** | **មុន្នី** | ជាប្រធាន |
| ២- លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣- លោក | ប្រាក់ | គីមសាន | ជាចៅក្រម |
| ៤- លោក | ប៉ែន | សារឿន | ជាចៅក្រមរបាយការណ៍ |
| ៥- លោក | យូរ | ឧត្តរា | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា ធន់ វណ្ណធឿន

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ១៩៨ "ឈ" ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៩៧០ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាង :

- ដើមចោទឈ្មោះ អ៊ឹម កុសល ហៅ យិន កុសល ដើមបណ្តឹងសាទុក្ខ ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ និស្សិត ទីលំនៅផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

ឪពុកឈ្មោះ យិន សាវ៉ាត " ស " ម្ដាយឈ្មោះ ចៅង សាម៉េត " រ " នៅលើរ ។

មានមេធាវី លោក ចាន់ សុខយាង

- និងចុងចម្លើយ ឈ្មោះ សៀង ចន្ធី ចុងបណ្ដឹងសាទុក្ខ ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរ រត់ម៉ូតូឌុប ទីលំនៅផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ សៀង ហ៊ាង " ស " ម្ដាយឈ្មោះ អ៊ុំ សាន " ស " ប្រពន្ធឈ្មោះ ស្បោង ចិន្តា មានកូន ៤នាក់ ។

មានមេធាវី លោក សោម ច័ន្ទឌីណា

អំពីវិវាទ : ប្ដឹង ទាមទារបែងចែកទ្រព្យមរតក ផ្ទះលេខ៥ ផ្លូវ ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ និង ប្ដឹងសុំឱ្យ សៀង ចន្ធី និង ប្រពន្ធ ព្រមទាំងកូនចុះចេញពីផ្ទះ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤៦៥ ចុះថ្ងៃទី០៤ខែ ធ្នូឆ្នាំ ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់លោក មេធាវី សុន អរុណ (តំណាងឱ្យឈ្មោះ អ៊ឹម កុសល ) មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៥៨ " ឈ " ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

- តាមពាក្យបណ្ដឹង ចុះថ្ងៃទី ២៥-០២-២០០១ របស់ដើមចោទឈ្មោះ អ៊ឹម កុសល ថា : ខ្លួនប្ដឹងសុំឱ្យឈ្មោះ សៀង ចន្ធី និង ប្រពន្ធឈ្មោះ ស្បោង ចិន្តា ព្រមទាំងកូន ចុះចេញពីផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលពីម្ដាយខ្លួន ( ម្ដាយចិញ្ចឹមឈ្មោះ អ៊ុំ សាន ) នៅរស់ គាត់បានឱ្យឈ្មោះ សៀង ចន្ធី មកស្នាក់នៅបណ្ដោះអាសន្ន ។ លុះដល់ថ្ងៃទី ០១-៥-៩៧ ម្ដាយរបស់ខ្លួនស្លាប់ ពេលនោះ ខ្លួនឱ្យឈ្មោះ សៀង ចន្ធី និងប្រពន្ធកូនចុះចេញពីផ្ទះរបស់ខ្លួន ព្រោះឈ្មោះ នេះ ពុំមានសិទ្ធិស្នាក់នៅក្នុងផ្ទះនេះបន្តទៀតឡើយ ។

ប៉ុន្តែ ត្រូវឈ្មោះ សៀង ចន្ធី បដិសេធមិនព្រមចុះចេញ ហើយបែរជាទារឱ្យខ្លួនប្រគល់ប្រាក់ឱ្យគាត់ចំនួន ៣០.០០០ $US ទើបគាត់ព្រមចុះចេញពីផ្ទះរបស់ខ្លួន ។

- តាមពាក្យបណ្ដឹងបន្ថែម ចុះថ្ងៃទី ១២-១១-២០០១ របស់ដើមចោទ ឈ្មោះ អ៊ឹម កុសល ថា : ខ្លួនប្ដឹងទាមទារបែងចែកមរតកនូវផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ពីឈ្មោះ សៀង ចន្ធី និង ប្រពន្ធឈ្មោះ ស្បោង ចិន្តា ដែលជាទ្រព្យសម្បត្តិរបស់ម្ដាយចិញ្ចឹមខ្លួនឈ្មោះ អ៊ុំ សាន បានបន្សល់ទុក ។

ដោយហេតុថា កាលពីឆ្នាំ ១៩៧៩ ម្ដាយចិញ្ចឹមរបស់ខ្លួន ជាស្ត្រីមេម៉ាយ បានចូលមករស់នៅក្នុងផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក នេះ ដូចមានប័ណ្ណគ្រួសារលេខ ២១៧ សៀវភៅលេខ ៣១/២៤-

០១-១៩៨១ បញ្ជាក់ជូនស្រាប់ ដែលមានឈ្មោះ គាត់ជាមេគ្រួសារ និងមានខ្លួនប្អូន១ របស់គាត់នៅក្នុងបន្ទុកហើយ នៅក្នុងឆ្នាំ ១៩៨២ ម្ដាយចិញ្ចឹមរបស់ខ្លួនបានយកប្ដីមួយទៀត ឈ្មោះ សៀង ហ៊ាង ។

ក្នុងរយៈពេល គាត់រស់នៅជាមួយ សៀង ហ៊ាង កូនដើមរបស់ សៀង ហ៊ាង ឈ្មោះ សៀង ចន្ទី ពុំបានមករស់នៅជាមួយឡើយ គ្រាន់តែយូរៗ មកលេងឪពុកម្ដង ចំណែកខ្លួនបានរស់នៅជាមួយម្ដាយចិញ្ចឹមជាប់រហូត។ នៅថ្ងៃទី ១២-០២-៩៧ ម្ដាយចិញ្ចឹមរបស់ខ្លួន បានចែកដីទំហំ ១៥ម គុណ ១៩មុ៨០ ស្ថិតក្នុងដីឡូត៍លេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ឱ្យទៅប្អូនគាត់ឈ្មោះ យិន សាវ៉ាត ដូចមានលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១២-០២-៩៧ ដោយមានលោកចៅសង្កាត់ ឈ្មោះ ប្រាក់ សារីម ចុះហត្ថលេខា ដឹងឮទៀតផង បន្ទាប់មក នៅថ្ងៃទី ០១-៥-៩៧ ម្ដាយចិញ្ចឹមខ្លួនបានស្លាប់ ដោយពុំបានធ្វើបណ្ដាំមរតកឡើយ ចាប់ពីពេលនោះមកឈ្មោះ សៀង ហ៊ាង ដែលជាឪពុកចុងរបស់ខ្លួន នៅគ្រប់គ្រង ។ ក្នុងរយៈពេលនោះឈ្មោះ សៀង ចន្ទី ឧស្សាហ៍មកលេងឪពុកឈ្មោះ សៀង ហ៊ាង រួច បានចូលមករស់នៅក្នុងបន្ទប់មួយក្នុងផ្ទះលេខ ៥ នេះ ។

ចាប់តាំងពីឈ្មោះ សៀង ចន្ទី ចូលមករស់នៅ គឺតែងតែមានទំនាស់ជាមួយខ្លួន ក្រោយមកទៀត នៅថ្ងៃទី ១៨-០៩-២០០០ ឪពុកចុងចិញ្ចឹមរបស់ខ្លួនឈ្មោះ សៀង ហ៊ាង ក៏បានស្លាប់ទៀត ។ ចាប់ពីពេលនោះមកឈ្មោះ សៀង ចន្ទី អាងយ៉ាងចង់គ្រប់គ្រងផ្ទះលេខ ៥ ទាំងមូល តែម្នាក់ឯង ដោយគេអះអាងថា ផ្ទះនេះជា ផ្ទះរបស់ឪពុកគេ ហើយគេមើលមកខ្លួនជាសត្រូវរបស់គេទាំងពីរនាក់ប្ដីប្រពន្ធ ឃើញភាពលោភលន់យ៉ាងដូច្នេះ ទើបខ្លួនសំរេចចិត្តប្ដឹងមកតុលាការ ដើម្បីសុំឱ្យតុលាការ ធ្វើការបែងចែកមរតករបស់ម្ដាយចិញ្ចឹមខ្លួន ឈ្មោះ អ៊ុំ សាន បានបន្សល់ទុកទៅតាមផ្លូវច្បាប់ ។

- តាមបណ្ដឹងតប ចុះថ្ងៃទី ២៧-០៤-២០០២ របស់មេធាវី សោម ច័ន្ទឌីណា ជាមេធាវីតំណាងឱ្យឈ្មោះ សៀង ចន្ទី បញ្ជាក់ថា: ខ្លួនប្ដឹងតបទៅនឹងពាក្យបណ្ដឹង ចុះថ្ងៃទី ២៥-០២-២០០១ និង បណ្ដឹងបន្ថែមចុះថ្ងៃទី ១២-១១-២០០១ របស់ឈ្មោះ អ៊ុម កុសល ដែលទាមទារយកចំណែកមរតក នៃ ផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ជាមួយកូនក្ដីខ្លួនឈ្មោះ សៀង ចន្ទី។ ដោយហេតុថា ឈ្មោះ សៀង ចន្ទី ជាកូនបង្កើតរបស់ឈ្មោះ សៀង ហ៊ាង និង នាង សួន សុខុម " បច្ចុប្បន្នស្លាប់ " ឈ្មោះ សៀង ហ៊ាង បានគ្នាជាប្ដីប្រពន្ធជាមួយឈ្មោះអ៊ុំ សាន តាំងពីឆ្នាំ ១៩៧៩ លុះដល់ឆ្នាំ ១៩៨០ ក៏បានរៀបការពេញច្បាប់ ហើយរស់នៅជាមួយគ្នាគ្រប់គ្រងផ្ទះលេខ ៥ ផ្លូវលេខ៤៣៦ ដោយមានឈ្មោះ សៀង ចន្ទី ជាកូននៅក្នុងបន្ទុក តែពុំមានអ្នកណាម្នាក់មករស់នៅជាមួយជាប់លាប់ទេ ។

ឈ្មោះ សៀង ហ៊ាង និង អ៊ុំ សាន បានជួលផ្ទះមួយផ្នែកឱ្យទៅឈ្មោះ មាស ឈ្យូក និង ឈ្មោះ ជួប ពៅ ហើយទទួលប្រាក់ឈ្នួលផ្ទះជួលរហូតមក ឈ្មោះ សៀង ចន្ទី ដែលជាកូនក្ដីរបស់ខ្លួន បានស្នាក់នៅខាងក្រោមជាមួយប្រពន្ធឈ្មោះ ស្បោង ចិន្ដា មានកូន ០៤នាក់ ក្នុងបន្ទុក ។ ដោយឡែកឈ្មោះ ថោង សាម៉េត មាន

គ្រួសារក៏ទៅនៅខាងប្ដី ពុំដែលរស់នៅជាមួយឡើយ និងអ៊ឹម កុសល ជាកូន ។ ឈ្មោះ អ៊ឹម កុសល នេះ គឺ ជាកូនរបស់ឈ្មោះ ចៅង សាម៉េត មិនមែនជាកូនរបស់ឈ្មោះ អ៊ុ សាន ទេ គឺគ្រាន់តែជាក្មួយតែប៉ុណ្ណោះ ។

នៅថ្ងៃទី ០១-៥-៩៧ ឈ្មោះ អ៊ុ សាន ដែលត្រូវជាប្រពន្ធឈ្មោះ សៀង ហ៊ាង រស់នៅជាមួយកូនបង្កើត សៀង ចន្ទី និង កូនប្រសារ ស្រី និង ចៅ ហើយទទួលប្រាក់ឈ្នួលផ្ទះរហូតមក និង ជួលឱ្យអ្នកផ្សេងទៀតដោយសុខចិត្តស្នាក់នៅក្នុងបន្ទប់តូចមួយ ហើយឈ្មោះ សៀង ចន្ទី នៅខាងក្រោមដដែល ។ នៅក្នុងចន្លោះឆ្នាំ ១៩៩៧ នេះ គ្មាននរណាមករស់នៅជាមួយទេ ក្រៅពីមកលេងធម្មតា ទៅមកទៅមក ស្រាប់តែមានឈ្មោះ យិន-សាវ៉ាត ដែលត្រូវជាប្ដីរបស់ឈ្មោះ ចៅង សាម៉េត មកទាមទារថា ជាដីរបស់ខ្លួន ហើយតាំងខ្លួនជាមេគ្រួសារ តែមិនបានស្នាក់នៅឡើយ ។

ក្នុងរយៈពេល ៣ឆ្នាំ ឈ្មោះ សៀង ហ៊ាង និង សៀង ចន្ទី ស្នាក់នៅរហូតមកទល់ថ្ងៃទី ១៨-៩-២០០០ ឈ្មោះ សៀង ហ៊ាង ក៏ស្លាប់បាត់ទៅទៀត គឺនៅសល់តែឈ្មោះ សៀង ចន្ទី និង ប្រពន្ធស្នាក់នៅជាកម្មសិទ្ធិស្រាប់តែមានឈ្មោះ អ៊ឹម កុសល មកទាមទារជារបស់ខ្លួនទៀត ដោយអួតអាងថា ខ្លួនគឺជាកូនចិញ្ចឹមរបស់ឈ្មោះ អ៊ុ សាន ហើយមកទាមទារចំណែកមរតក ដែលឈ្មោះនេះ គឺគ្រាន់តែជាក្មួយ និង មិនដែលរស់នៅជាមួយសោះ ។

តបតាមខ្សែលោហិតបន្តមរតក មានតែឈ្មោះ សៀង ចន្ទី តែម្នាក់គត់ ដែលជាកូនបង្កើតរបស់លោក សៀង ហ៊ាង ដែលជាអ្នកទទួលស្នង រីឯលោក សៀង ហ៊ាង និង អ៊ុ សាន ពុំមានកូនទេ ហើយឈ្មោះ សៀង ចន្ទី ក៏បានស្នាក់នៅជាមួយរហូតទល់ពេលឪពុក-ម្ដាយស្លាប់ ក៏អាចក្លាយ ជាម្ចាស់កម្មសិទ្ធិទៅហើយ ។

ខ្លួនសុំបដិសេធ លើបណ្ដឹង និងបណ្ដឹងបន្ថែម របស់ឈ្មោះ អ៊ឹម កុសល ចោលដោយសុំឱ្យតុលាការសំរេចផ្ដល់មរតកផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក មកឱ្យកូនក្ដីខ្លួនឈ្មោះសៀង ចន្ទី ជាកម្មសិទ្ធិពេញច្បាប់ផងចុះ ។

បានឃើញ ដីកាសំរេចកិច្ចការប្រញាប់ លេខ ១២ប្រ " ង " ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលសំរេច :

១- ទទួលពាក្យបណ្ដឹងកិច្ចការប្រញាប់ ចុះថ្ងៃទី ២៥-៥-២០០១ របស់ដើមចោទឈ្មោះ អ៊ឹម កុសល ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ហាមឃាត់ឈ្មោះ សៀង ចន្ទី និង ប្រពន្ធឈ្មោះ ស្បោង ចិន្ដា មិនឱ្យលក់-ដូរ បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយដល់អ្នកដទៃនូវផ្ទះលេខ ៥ ផ្លូវលេខ ៤៣៦ ក្រុម២១ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ជាបណ្ដោះអាសន្ន រង់ចាំតុលាការសំរេចដល់អង្គសេចក្ដីជាស្ថាពរ ។

៣- បង្គាប់ឱ្យឈ្មោះ អ៊ឹម កុសល បង់ប្រាក់ប្រដាប់ក្ដីចំនួន ៤០០០រៀល គឺពន្ធហ្វឹង និង ពន្ធចុះបញ្ជីក្ដីចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល និង រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ២០០០រៀល

ប្រាក់នេះកាត់យកពីប្រាក់ដែលដើមចោទ បានបង់ទុកជាស្រេច ។

៤- ដីកាសំរេចនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥- ដីកាសំរេចនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ចាប់ពីថ្ងៃនេះ តទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណី លេខ ០៣ " ង " ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៥-០២-២០០១ និង បណ្តឹងបន្ថែម ចុះថ្ងៃទី ១២-១១-២០០១ របស់ដើមចោទឈ្មោះ អ៊ឹម កុសល តំណាងដោយមេធាវីឈ្មោះ សុន អរុណ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- ទទួលស្គាល់មេធាវីឈ្មោះ សុន អរុណ ជាតំណាងសិទ្ធិរបស់ដើមចោទតាមលិខិតចុះថ្ងៃទី ២៦-៣-២០០៣ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលពាក្យបណ្តឹងតប និង បន្ថែមុ ចុះថ្ងៃទី ១២-១១-២០០១ របស់ចុងចម្លើយឈ្មោះ សៀង-ចន្ទី តំណាងដោយមេធាវី សោម ច័ន្ទឌីណា ចុះថ្ងៃទី ២៧-៤-២០០២ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់និង បដិសេធចោលដោយផ្ទុយគតិច្បាប់ ។

៤- ទទួលស្គាល់មេធាវីឈ្មោះ សោម ច័ន្ទឌីណា ជាតំណាងរបស់ចុងចម្លើយឈ្មោះ សៀង ចន្ទី តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ០៤-៤-២០០២ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥- ទទួលស្គាល់ប័ណ្ណគ្រួសារលេខ ២១៧ ចុះថ្ងៃទី ២៤-០១-១៩៨១ តាមសៀវភៅលេខ៣១ របស់គណៈកម្មាធិការប្រជាជនបដិវត្តក្រុង ជាត្រឹមត្រូវដោយចាត់ទុកថា ផ្ទះលេខ ៥ ផ្លូវ ៤៣៦ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ជាទ្រព្យសម្បត្តិដោយឡែករបស់សពឈ្មោះ អ៊ុំ សាន ដែលត្រូវជាម្តាយចិញ្ចឹមឈ្មោះ អ៊ឹម កុសល ប្រាកដមែន ។

៦- សំរេចប្រគល់ផ្ទះលេខ៥ ផ្លូវ៤៣៦ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ឱ្យទៅឈ្មោះ អ៊ឹម កុសល ដែលត្រូវជាកូនចិញ្ចឹមសពឈ្មោះអ៊ុំ សាន កាន់កាប់ និងប្រើប្រាស់ ចាប់ពីសាលក្រមនេះចូលជាស្ថាពរ ។

៧- បង្គាប់ឱ្យឈ្មោះ សៀង ចន្ទី បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ១៨០០រៀល ប្រាក់ចំណាយលើដីកាកោះ ៥០០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល សរុប ៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០ រៀល ដែលដើមចោទ បានបង់រួច និង រឹបអូសប្រាក់ប្រដាប់ក្តី ដែលបានបង់រួចចំនួន ៧០០០រៀល ។

កាលបើហួសឧទ្ធរណ៍ ត្រូវបង្គាប់ឱ្យឈ្មោះ សៀង ចន្នី សងប្រាក់នេះ ទៅដើមចោទវិញ និង បង្គាប់ឱ្យបង់ពន្ធសមាមាត្រ ១% លើតំលៃផ្ទះជាក់ស្តែង ប្រាក់នេះត្រូវបង្វិលចូលថវិការដ្ឋ ៨០% និង រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ប្រាក់នេះត្រូវឱ្យដើមចោទបង់ទុកជាមុន ទើបបង្គាប់ឱ្យចុងចម្លើយសងជាក្រោយ ។

៨- សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខមេធាវីតំណាងឱ្យដើមចោទ និង ដើមចោទ មេធាវីតំណាងចុងចម្លើយ និង ចុងចម្លើយ បើកផ្លូវប្តឹងឧទ្ធរណ៍តាមច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ០៥ " ឍ " ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៣ របស់សោម-ច័ន្ទឌីណា មេធាវីការពារឱ្យ ចុងចម្លើយ មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៣ "ង "ចុះថ្ងៃទី០២ខែមករា ឆ្នាំ ២០០៣ របស់តុលាការក្រុងភ្នំពេញលើត្រង់ចំណុច នៃ សាលក្រម ទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១៥៨ " ឈ " ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤-០២-២០០៣ របស់លោក មេធាវី សោម ច័ន្ទឌីណា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ០៣ " ង " ចុះថ្ងៃទី ០២-០១-២០០៣ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣- ប្រគល់ផ្ទះទំនាស់លេខ ៥ ផ្លូវលេខ ៤៣៦ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ឱ្យទៅឈ្មោះ សៀង ចន្នី កាន់កាប់គ្រប់គ្រង និង ប្រើប្រាស់តទៅ ។

៤- កាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលចុងចម្លើយបានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង អាជ្ញាធរចំនួន ៥.០០០រៀល ។ នៅពេលសាលដីកានេះ ចូលជាស្ថាពរបង្គាប់ឱ្យដើមចោទបង់ប្រាក់ចំនួន ១៣.០០០រៀល នេះ ទៅចុងចម្លើយវិញ និង បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ ១% លើផ្ទះទំនាស់ ។

៥- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១៧-១០-២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២២-១០-២០០៣ ចំពោះមុខមេធាវី តំណាងគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់លោក មេធាវី សុន អរុណ ( តំណាងឱ្យឈ្មោះ អ៊ឹម កុសល ) មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៥៨ " ឈ " ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើ សាលដីកាទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៤ របស់ លោក អ៊ឹម កុសល

បានឃើញ សារណាតប ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤ របស់លោក សៀង ចន្ធី

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់ ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។
- សាលដីការដ្ឋប្បវេណីលេខ ១៥៨ "ឈ" ចុះថ្ងៃទី ២២-១០-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយរបស់លោក អ៊ឹម កុសល បានឆ្លើយថា: ដោយសាលាឧទ្ធរណ៍កាត់ក្តីពុំបានត្រឹមត្រូវ ដោយផ្ទះនេះ គឺកេរ្តិ៍របស់ម្តាយចិញ្ចឹមខ្លួន ហើយខ្លួនក៏បានមករស់នៅតាំងពី ៧៩ មកម្លេះ ពេលនោះខ្លួនមានអាយុប្រហែល ៥ឆ្នាំ ហើយ ។ ម្តាយរបស់ខ្លួនបង្កើតឈ្មោះ ថោង សាម៉េត ហើយគាត់បានយកប្តីចុងទៀតឈ្មោះ យិន សាវ៉ាត ដូចនេះ ទើបគាត់ត្រូវប្តូរត្រកូលរបស់ខ្លួនទៅជា យិន កុសល វិញ ប៉ុន្តែខ្លួនក៏បានបញ្ជាក់ហើយដែរ តាំងពីតុលាការថ្នាក់ក្រោម រហូតដល់តុលាការកំពូល គឺខ្លួនប្រើឈ្មោះ អ៊ឹម កុសល ហៅ យិន កុសល ។ ចំណែកឯម្តាយចិញ្ចឹមរបស់ខ្លួនវិញ គាត់ឈ្មោះ អ៊ី សាន ហើយគាត់បានសុំខ្លួនដែលត្រូវជាក្មួយបង្កើតរបស់គាត់ទៅធ្វើជាកូនចិញ្ចឹម និង ចេញទៅរស់នៅជាមួយគាត់ នៅសាលាវត្តកោះជាបណ្តោះអាសន្នទេ ។ ការរស់នៅរបស់ខ្លួនគឺ គាត់ទាំងពីរនាក់ជាអ្នកមានគុណខ្លួនទាំងពីរដូចគ្នា ព្រោះម៉ែ ១ ឧបត្ថម្ភនេះ ម៉ែ១ ឧបត្ថម្ភនោះ ។ ម៉ែឈ្មោះ អ៊ី សាន បានបែងចែកដីឱ្យប្អូនបង្កើតរបស់ឈ្មោះ ថោង សាម៉េត ដែលមានទំហំ ១៥ម ×១៥, ៨០ម ដោយមានបញ្ជាក់ពីអាជ្ញាធរដឹងឮត្រឹមត្រូវ ។ ដំបូងនៅក្នុងសៀវភៅស្នាក់នៅមានសមាជិក ១១នាក់ តែក្រោយមកគេក៏ចេញទៅរស់នៅអឺរីយ៍ក្សត្រ អស់ទៅ នៅតែ ៤នាក់ ទេ ដូចមានស្នាមឈូតឈ្មោះនោះ គឺ ជាឈ្មោះ ដែលត្រូវលុបចោល នៅក្នុងសៀវភៅ ឆ្នាំ ៨១ ។ ក្នុងផ្ទះនេះ ក៏មានឈ្មោះ សេង សើរ និង ប្រពន្ធ បានមករស់នៅ ដោយអាជ្ញាធរមូលដ្ឋានបញ្ជាក់ដឹងឮ ក្រោយមកប្រពន្ធ សេង សើរ បានស្លាប់ទៅ គាត់ក៏លក់ឱ្យ កុល ផល្លា បន្ត។ ខ្លួនដឹងត្រឹមថា មានអ្នកមកជួលផ្ទះ ក្រោយពេលម្តាយខ្លួនចេញទៅនៅវត្តកោះ ហើយ សៀង ចន្ធី ក៏បានមកជួលនៅខាងលើ ខ្លួនពុំបានចាំពីឆ្នាំខែ ដែលគេមកជួលនោះទេ ។

បានស្តាប់ចម្លើយរបស់ លោក សៀង ចន្ធី បានឆ្លើយថា : ផ្ទះនេះ ខ្លួននៅតាំងពី ៨១មកម្លេះ នៅពេលខ្លួនទៅរស់នៅនោះ ក៏មានឈ្មោះ អ៊ឹម កុសល នៅដែរ ពេលខ្លួនមករស់នៅនេះ គឺឪពុកឈ្មោះ សៀង ហ៊ាង និង ឈ្មោះ អ៊ី សាន បានទៅយកខ្លួនមកនៅ ពេលនោះដែរខ្លួនមានអាយុជាង ១០ ឆ្នាំ ហើយ ។ ក្រោយមកពួកគេផ្សេងទៀតបានចេញអស់ហើយ ខ្លួនពុំបានដឹងថា ពួកគេទៅរស់នៅកន្លែងណាទេ ប៉ុន្តែខ្លួនគ្រាន់តែដឹងថា នៅពេលម្តាយខ្លួនឈ្មោះ អ៊ី សាន នេះស្លាប់ គឺគាត់ទៅស្លាប់នៅអឺរីយ៍ក្សត្រ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ចាន់ សុខយាង ការពារឱ្យដើមចោទ បញ្ជាក់ថា :

ទាក់ទងនឹងរឿងនេះ ខ្លួនសូមញែកចែកចេញជាពីរ គឺ :

- បញ្ហាសិទ្ធិកាន់កាប់ គឺមានឈ្មោះ អ៊ុំ សាន និង សមាជិករបស់គាត់ មាន១១នាក់ ហើយក្នុង១១នាក់នេះ គឺគ្មានឈ្មោះ សៀង ចន្ធី ទេ ពីឆ្នាំ ៧៩មក ។

- បញ្ហាដែលទាក់ទងនឹងទ្រព្យមរតកគឺ នៅឆ្នាំ ៩៤ ក្នុងប័ណ្ណគ្រួសារ ទើបឃើញមានឈ្មោះ សៀង-ហ៊ាង និង សៀង ចន្ធី ។ ខ្លួនសូមបញ្ជាក់ផងដែរថា នៅក្នុងឆ្នាំ ៨២ ឈ្មោះ សៀង ហ៊ាង នៅមានប្រពន្ធដើមគាត់នៅឡើយទេ ហើយទំនាក់ទំនងរវាង សៀង ហ៊ាង និង អ៊ុំ សាន នេះ មានលក្ខណៈជាប្តីប្រពន្ធលួចលាក់ទេ ហើយសៀង ហ៊ាង មករស់នៅក្រោយឈ្មោះ អ៊ុំ សាន ទេ ដូចនេះផ្ទះនេះជាកម្មសិទ្ធិរបស់ អ៊ុំ សាន ។ ផ្ទះនេះដំបូងឡើងគឺមាន ៣គ្រួសារ មករស់នៅ គឺ អ៊ុំ សាន , ថោង សាម៉េត , សេង សេរី ហើយ សេង សេរី បានលក់បន្តឱ្យ កុល-ផល្លា ដូចនេះសៀង ហ៊ាង គ្មានសិទ្ធិទាមទារផ្ទះនេះជាកម្មសិទ្ធិរបស់គាត់ទេ រីក៏គ្មានសិទ្ធិទាមទារជាទ្រព្យរួមដែរ ។ ទ្រព្យរបស់ អ៊ុំ សាន គឺត្រូវធ្លាក់ទៅលើសាច់ញាតិគាត់សិន ទើបធ្លាក់ទៅលើទាយាទរបស់គាត់ ។ ឈ្មោះ អ៊ុំ សាន បានស្លាប់នៅខែ ៥-១៩៩៧ ហើយតាមលិខិតដែល អ៊ុំ សាន បានចុះឈ្មោះ អ៊ឹម កុសល ជាកូនចិញ្ចឹម ហើយតាមគោលការណ៍ច្បាប់ អ៊ឹម កុសល ជាអ្នកទទួលមរតក ។ ឈ្មោះ ថោង សាម៉េត មានសិទ្ធិលើដីទំហំ ១៥ម គុណ ១៩, ៨០ម និង ឈ្មោះ កុល ផល្លា ដែលគេជាម្ចាស់កម្មសិទ្ធិត្រឹមត្រូវ ហើយសាលាឧទ្ធរណ៍បានសំរេចពុំត្រឹមត្រូវទេ គឺវាប៉ះពាល់ដល់ផលប្រយោជន៍ ២នាក់ទៀត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សោម ច័ន្ទឌីណា ជាមេធាវី ការពារឱ្យ ចុងចម្លើយ បញ្ជាក់ថា: ខ្លួនសូមបញ្ជាក់ថា រឿងនេះ ខ្លួនបានដឹងច្បាស់លាស់ណាស់ គឺមាន ៣តំណាក់កាលមកហើយដែលខ្លួនបានដឹង :

នៅឆ្នាំ ៧៩ ឈ្មោះ អ៊ុំ សាន ជាអ្នកកាន់កាប់មែន ប៉ុន្តែពេលនោះ វាជាទ្រព្យរបស់រដ្ឋ មិនមែនជារបស់បុគ្គលណាទេ ។ ថ្វីត្បិតតែគាត់ពុំទាន់ បានចងសម្ព័ន្ធជាប្តីប្រពន្ធនឹងគ្នា តែក្រោយមកគាត់ក៏បានចុះបញ្ជីជាប្តីប្រពន្ធ ដោយមានអាជ្ញាធរដឹងឮ ។ បើឈ្មោះ អ៊ឹម កុសល ជាកូនចិញ្ចឹម តើ អ៊ុំ សាន ជាអ្នកបីបាច់ថែរក្សាឬទេ ? ប៉ុន្តែគ្មានអាជ្ញាធរណាទទួលស្គាល់ថា អ៊ឹម កុសល ជាកូនចិញ្ចឹមទេ ចំណែក ថោង សាម៉េត នោះជាប្អូនថ្លៃទេ មិនមែនប្អូនបង្កើតទេ ។ មានលិខិត ដែលចុះឈ្មោះ អ៊ុំ សាន ជាប្រពន្ធ និង សៀង ហ៊ាង ជាប្តីផងដែរ ហើយ សៀង ចន្ធី ជាកូនរបស់ សៀង ហ៊ាង ហើយ អ៊ុំ សាន ក៏ស្រលាញ់សៀង ចន្ធី ជាកូនដែរ ។ ហើយ សៀង ចន្ធី បានជាជួងជាមួយឪពុកបាន ១២ដើម ហើយក្រោយមកក៏បានដាចេក ជុំវិញផ្ទះ ចាក់ដីបំពេញ ធ្វើបណ្តាញលូទឹក សព្វថ្ងៃនេះ ផ្ទះទំនាស់នេះទ្រុឌទ្រោមយ៉ាងខ្លាំង ។ ឈ្មោះ អ៊ុំ សាន បានចែកដីឱ្យនោះ គួរតែប្រគល់ឱ្យ អ៊ឹម កុសល ហេតុអ្វីក៏ប្រគល់ទៅឱ្យ ថោង សាម៉េត និង យិន សារ៉ាត ទៅវិញ ។ ការផ្ទេរសិទ្ធិប្រគល់ដីឱ្យ យិន សារ៉ាត និងថោង សាម៉េតនេះ ឈ្មោះ សៀង ហ៊ាង ជាប្តីសុំបដិសេធទាំងស្រុងចោល នៅអាជ្ញាធរមូលដ្ឋានរួចហើយ ។ តាមលិខិតបញ្ជីរបស់

លោក សុខ ស៊ី ថា : "ឈ្មោះ សេង សេរី ស្នាក់នៅនោះ បើម្ចាស់កម្មសិទ្ធិនោះទាមទារយកវិញ គាត់សន្យាថានឹងសងវិញ " ។ ខ្លួនសូមបង្ហាញសៀវភៅគ្រួសារ ដែលចុះហត្ថលេខា ឆ្នាំ ២០០១ ។ ពេលលោក យិន សាវ៉ាត ស្លាប់ទៅ លោក យិន កុសល ពុំទាន់ផ្លាស់ប្តូរត្រកូលទៅជា អ៊ឹម កុសល នៅឡើយទេ ហើយក្រោយមក អ្នកស្រី ថោង សាម៉េត ក៏បានទៅសុំលុបឈ្មោះ ប្តីឈ្មោះ យិន សាវ៉ាត នេះចោល ហើយក៏សុំប្តូរត្រកូលឱ្យកូនជាមួយប្តីដើមវិញ។ ចម្លើយសាក្សី រដ្ឋអំណាចមូលដ្ឋាន បានបញ្ជាក់ថា គាត់ទាំងពីរនាក់នេះ ពិតជាប្តីប្រពន្ធនឹងគ្នា ដូចនេះ គាត់ក៏ត្រូវក្លាយទៅជាម្ចាស់កម្មសិទ្ធិរួចទៅហើយ ព្រោះវា ជាទ្រព្យសម្បត្តិរួម ហើយពីឆ្នាំ ៨៩ រហូតមកដល់ពេលស្លាប់នោះគឺរយៈពេល ១០ឆ្នាំ ហើយ ។ នៅឆ្នាំ ៩២ មក គឺគ្មានឈ្មោះ អ៊ឹម កុសល ចុះក្នុងសៀវភៅគ្រួសារទេ ។

សូមលោកចៅក្រម មេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ចាន់ សុខយាង ជាមេធាវីការពារឱ្យដើមចោទបញ្ជាក់បន្ថែមទៀតថា : បើសិនជានៅឆ្នាំ ៨១ មុនចេញអនុក្រឹត្យនោះ គឺជាទ្រព្យរបស់រដ្ឋ ចុះហេតុអ្វីក៏មិនចុះឈ្មោះពីពេលនោះមក ហើយចាំមកចុះនៅឆ្នាំ ៩៤ ទៅវិញ ។ បញ្ហាលោក អ៊ឹម កុសល ជាកូនចិញ្ចឹមនោះ ក៏មានសាក្សីបំភ្លឺថា លោក អ៊ឹម កុសល នៅជាមួយឈ្មោះ អ៊ុ សាន រហូតដល់ស្លាប់ ហើយ អ៊ឹម កុសល ត្រូវរស់នៅដោយ អ៊ុ-សាន ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា។ ឈ្មោះ ថោង សាម៉េត ជាប្អូនបង្កើតរបស់ អ៊ុ សាន គឺគាត់ចែកឱ្យដាច់តែម្តងហើយ សេង សេរី បានមកស្នាក់នៅពីឆ្នាំ ៨០ មុនអនុក្រឹត្យចេញទៅទៀត ឯបញ្ហាបន្ទប់ជួលទាំងប៉ុន្មាននោះគឺបន្ទប់ចាក់សោរចោល ពុំបានជួលឱ្យអ្នកណាទេ ហើយនៅឆ្នាំ ៩៤ ឈ្មោះ អ៊ុ សាន ក៏បាននៅតែចុះឈ្មោះ អ៊ឹម កុសល ជាកូនចិញ្ចឹមទៀត ។

ខ្ញុំសូមសំណូមពរ :

១- ត្រូវរកឱ្យឃើញថា ទ្រព្យនោះជាទ្រព្យរបស់អ្នកណា

២- ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់

ខ្លួនសូមតម្កល់សារណារបស់ខ្លួននៅដដែល និង សូមបង្វិលសំណុំរឿង ទៅសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សោម ច័ន្ទឌីណា ជាមេធាវីការពារឱ្យចុងចម្លើយ បញ្ជាក់បន្ថែមទៀតថា : បើសិនជា អ៊ឹម កុសល បានរស់នៅជាមួយអ៊ុ សាន រហូតគាត់ស្លាប់ ហេតុអ្វីក៏លោក អ៊ឹម កុសល ថា លោករស់នៅផ្ទះលេខ៥ ... ទៅវិញ។ តាមពិត អ៊ុ សាន បានស្លាប់តែម្នាក់ឯងនៅអរិយក្សត្រទេគឺ អ៊ឹម កុសល ពុំបានទាន់ដង្ហើម អ៊ុ សាន ស្លាប់ទេ ។

សូមលោក ចៅក្រមមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់មេធាវី សុន-អរុណ តំណាងឱ្យដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ឈ្មោះ អ៊ឹម កុសល ក្នុងសារណា ចុះថ្ងៃទី ០៩-៣-០៤ ថា ឈ្មោះ អ៊ុំ សាន បានយកក្មួយបង្កើត គឺរូបខ្លួនមកធ្វើជាកូន ហើយបានចុះក្នុងប័ណ្ណគ្រួសារ មានអាជ្ញាធរដឹងឮ ហេតុនេះ ខ្លួនមានអានុភាពតាមផ្លូវច្បាប់ពេញលេញ ក្នុងការទទួលមរតកពីឈ្មោះ អ៊ុំ សាន ជាម្តាយនោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា ៖

+ ប័ណ្ណគ្រួសារលេខ ២១៧ សៀវភៅលេខ ៣១/២៤-០១-៨១ ដែលមានឈ្មោះ អ៊ឹម កុសល ជាកូននោះ ពុំមានលក្ខណៈគ្រប់គ្រាន់ អាចឱ្យតុលាការទទួលយកបានទេ ពីព្រោះនៅក្នុងប័ណ្ណគ្រួសារនេះ មានឈ្មោះសមាជិកគ្រួសារចំនួន០៦ នាក់ ទៀត ដែលដាក់ថា កូន ។

+ ម្យ៉ាងទៀត ដើម្បីទទួលឋានៈជាកូនចិញ្ចឹម ទោះបីកាលៈទេសៈនោះ ពុំទាន់មានច្បាប់ក៏ដោយក៏យ៉ាងហោចណាស់ កូនចិញ្ចឹមនេះ ត្រូវមាននាមត្រកូលទៅតាមនាមត្រកូលរបស់ឪពុក ឬ ម្តាយចិញ្ចឹម ហើយលោក អ៊ឹម កុសល ក៏ពុំស្ថិតនៅក្រោមអំណាចមេបារបស់សពលោកយាយ អ៊ុំ សាន ដែរ ។

+ មានភស្តុតាងបញ្ជាក់ថា នៅឆ្នាំ ១៩៨២ លោកយាយ អ៊ុំ សាន បានទទួលយកឈ្មោះ សៀង-ហ៊ាង ជាប្តី ដូច្នេះ ផ្ទះ និង ដី ពុំមែនជាកម្មសិទ្ធិរបស់ឈ្មោះ អ៊ុំ សាន តែម្នាក់ទេ គឺជាសហកម្ម-សិទ្ធិរវាងឈ្មោះ អ៊ុំ សាន និង ឈ្មោះ សៀង ហ៊ាង ។

- យល់ឃើញថា ផ្ទះទំនាស់នេះ ចុងចម្លើយបានកាន់កាប់ និង រស់នៅរួចហើយ ដូច្នេះពុំត្រូវឱ្យដើមចោទ បង់ពន្ធសមាមាត្រទៀតទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៥៨ " ឈ " ចុះថ្ងៃទី ២២-១០-២០០៣ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣២៦ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់លោកមេធាវី សុន -

អរុណាទុកជាត្រឹមត្រូវទាំងទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៥៨ " ឈ " ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងពន្ធសមាមាត្រ ដែលត្រូវទុកជាមោឃៈ ដោយឥតបង្វិល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដី ដែលដើមចោទ បានបង់រួចហើយនៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ីង ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥០០០ រៀល សរុប ១៩០០០ រៀល ។

៤- សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី ០៩ខែកញ្ញា ឆ្នាំ២០០៤ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ ២០០៤ ។